ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សុន្ទរកថាស្វាគមន៍
## របស់ឯកឧត្តមបណ្ឌិត ម៉ី វ៉ាន់ អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
## ថ្លែងក្នុងសន្និសីទមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ ស្តីពី
## កំណើនប្រកបដោយសុខភាពល្អដើម្បីការអភិវឌ្ឍមាននិរន្តរភាព

ថ្ងៃ ទី២៣ ខែធ្នូ ឆ្នាំ២០១៥, នៅសណ្ឋាគារឯករាជ្យ ខេត្ត ព្រះសីហនុ

**លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា**
**លោកឧកញ៉ា ប៊ុន មុនី ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ភ្ញៀវជាតិ-អន្តរជាតិ**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយឥតឧបមា ដោយបានចូលរួមក្នុងសន្និសីទមីក្រូហិរញ្ញវត្ថុ ប្រចាំឆ្នាំ ក្រោមប្រធានបទ "កំណើនប្រកបដោយសុខភាពល្អដើម្បីការអភិវឌ្ឍមាននិរន្តរភាព" ដែលត្រូវបានរៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ ខ្ញុំសូមថ្លែងអំណរគុណ និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាភ្ញៀវកិត្តិយស តំណាងក្រសួងស្ថាប័ន ពាក់ព័ន្ធ ធនាគារជាតិនៃកម្ពុជា ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសិក្ខាសាលាពេលនេះ។ សន្និសីទនេះ មានសារៈសំខាន់ដែលជាការជួបពិភាក្សាគ្នារវាងអ្នករៀបចំគោលនយោបាយ បញ្ញត្តិករ វិនិយោគិន ដៃគូអភិវឌ្ឍ និងស្ថាប័នផ្តល់សេវាហិរញ្ញវត្ថុ ដើម្បីស្វែងរកវិធានការដំដោះស្រាយសម្រាប់ជួយជំរុញវិស័យមីក្រូហិរញ្ញវត្ថុឱ្យមានកំណើនប្រកបដោយសុខភាពល្អដើម្បីការអភិវឌ្ឍមាននិរន្តរភាពចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមនិងកាត់បន្ថយនូវភាពក្រីក្រ។

ដូចឯកឧត្តម លោកជំទាវ លោក-លោកស្រី ជ្រាបស្រាប់ហើយថា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចំរើនយ៉ាងឆាប់រហ័សគួរជាទីមោទនៈ ទាំងផលិតផល សេវា គុណភាព និងបរិមាណបើប្រៀបធៀបរយៈពេលដូចគ្នានាឆ្នាំកន្លងទៅ÷

-ឥណទានសម្រាប់ត្រីមាសទី៣ ២០១៥ មានចំនួន ២.៧៣០ លានដុល្លារអាមេរិក កើនឡើង ៥២% ធៀបនិងរយៈពេលដូចគ្នាឆ្នាំ២០១៤

-ប្រាក់បញ្ញើ-សន្សំសម្រាប់ត្រីមាសទី៣ ២០១៥ មានចំនួន ១.២៤០ លានដុល្លារអាមេរិក កើនឡើង ៥៣% ធៀបនិងរយៈពេលដូចគ្នាឆ្នាំ២០១៤

-អតិថិជនសម្រាប់ត្រីមាសទី៣ ២០១៥ មានចំនួន ១,៩៣ លាននាក់ កើនឡើង ១៣% ធៀបនិងរយៈពេលដូចគ្នាឆ្នាំ២០១៤

ការរីកចំរើនទាំងនេះ បានមកពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំគោលនយោ-



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

បាយ និងក្របខណ្ឌគតិយុត្តនានា ព្រមទាំងមានការចូលរួមសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុខ្លួនឯង។ ទន្ទឹមនឹងការរីកចំរើននៃវិស័យមីក្រូហិរញ្ញវត្ថុនេះ ក៏ជួបនូវបញ្ហាប្រឈមមួយចំនួនត្រូវដោះស្រាយជាបន្ទាន់ ជាក់ស្តែងរាជរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចូលរួមអនុវត្តសកម្មភាពសំខាន់ៗ ដែលជាវឌ្ឍនភាពការងារក្នុងឆ្នាំ២០១៦ ដូចតទៅ÷

១.នៅខែមករា ឆ្នាំ២០១៥ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំស្តីពី ការពិនិត្យស្ថានភាព និងការរិះរកដំណោះស្រាយអំពីបញ្ហាប្រឈមបច្ចុប្បន្ន និងទៅអនាគតនៃហិរញ្ញប្បទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ នៅតាមរាជធានីនិងខេត្តនានា ពិសេសនៅតំបន់ជនបទ ក្រោមអធិបតីភាពឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ។ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារ២គឺ ***ក្រុមការងារទី១*** គឺដឹកនាំដោយក្រសួងមហាផ្ទៃ មានភារកិច្ចតាមដាន និងពង្រឹងការគ្រប់គ្រងការចុះបញ្ជីប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និង ***ក្រុមការងារទី២*** គឺដឹកនាំដោយធនាគារជាតិនៃកម្ពុជា មានភារកិច្ចសិក្សាអំពីលទ្ធភាព ដើម្បីបន្ថយអត្រាការប្រាក់ និងរៀបចំច្បាប់ បទប្បញ្ញត្តិចាំបាច់សម្រាប់ការពារអតិថិជន ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់ឥណទានដល់ប្រជាពលរដ្ឋងាយរងគ្រោះ។ បន្ទាប់មកនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ បានចេញសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ស្តីពីការបញ្ឈប់សកម្មភាពរបស់អង្គការ សមាគម និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ មួយចំនួនដែលមិនបានចុះបញ្ជីហើយបានធ្វើការផ្តល់សេវាឥណទានជនបទមិនគោរពក្រមសីលធម៌វិជ្ជាជីវៈដែលនាំឱ្យប៉ះពាល់ដល់ការអភិវឌ្ឍវិស័យទាំងមូល។

២.នៅខែកុម្ភៈ ឆ្នាំ២០១៥ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំប្រជុំស្តីពី ការកំណត់អត្រាការប្រាក់ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ក្រោមអធិបតីភាពឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ។ អង្គប្រជុំបានលើកឡើង នូវវិធានការរយៈពេលខ្លី និងរយៈមធ្យម ដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ប្រកបដោយមានតម្លាភាព។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏បានឆ្លើយតបទៅតំណាងរាស្ត្រគណៈបក្សសង្គ្រោះជាតិ ដែលបានលើកឡើងថាអត្រាការប្រាក់មីក្រូហិរញ្ញវត្ថុ នៅតែថ្លៃ។

៣.កសហវ និងគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) បានចេញលិខិតលេខ៣១៥៧ សហវ.អឧហ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ទៅក្រសួងមហាផ្ទៃ ចំពោះក្រុមហ៊ុនចំនួន០៤ រួមមាន ក្រុមហ៊ុន EBC ក្រុមហ៊ុន AIF ក្រុមហ៊ុន ICA និងក្រុមហ៊ុន ហ្វូត សុវណ្ណ គ្រុបខូអិលធីឌី និងបានចេញ សេចក្តីជូនដំណឹងរួមលេខ០១៤ **កសហវ និង គ.ម.ក** ជូនដល់សាធារណៈជនឱ្យបញ្ឈប់ការដាក់ប្រាក់សន្សំក្នុងរូបភាពជាគម្រោងវិនិយោគរួម ដែលក្រុមហ៊ុនទាំងនេះ មិនទាន់ទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា។

៤.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រជុំពិភាក្សាជាមួយនិងក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីរិះរកវិធានការដោះស្រាយបញ្ហាប្រជាជន ដែលឆ្លងមេរោគអេដស៍នៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង ជំពាក់បំណុលនិងការប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ករណីនេះរាជរដ្ឋាភិបាលបានឆ្លើយតបតាមការលើកឡើងតំណាងរាស្ត្រ គណបក្សសង្គ្រោះជាតិ។

៥.រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពី "ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ" និងសេចក្តី សម្រេចលេខ៨១ សសរ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ ស្តីពី "ការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ"។ គណៈកម្មាធិការនេះ មានភារកិច្ច ក្នុងការរៀបចំ និងអនុម័តគោលនយោបាយ និងយុទ្ធសាស្ត្រ

អភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ គណៈកម្មាធិការនេះនឹងរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០០៧ ដែលរៀបចំដោយគណៈកម្មាធិការឥណទានសម្រាប់អភិវឌ្ឍនជនបទ ដើម្បីឆ្លើយតបទៅនឹងភាពរីកចំរើននៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងបរិបទបច្ចុប្បន្ន និងនិន្នាការអនាគត។

៦.តាមរយៈអនុក្រឹត្យលេខ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពី "បរធនបាលកិច្ចហិរញ្ញវត្ថុ" និងប្រកាសលេខ១០៤១សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពី "ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ" ក្រសួងបានទទួលការចុះបញ្ជី បរធនបាលកិច្ចហិរញ្ញវត្ថុ ចំនួន ០៨ ក្នុងនោះរួមមាន÷ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ អម្រឹត ក្រេឌីត អង្គការអេស៊ីលីដា ស្ថាបនា ហត្ថាកសិករ អភិវឌ្ឍន៍តំបន់ពាយ័ព្យ និងសីលានិធិ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណដល់ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ខាងលើដែលមានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការចូលរួមអនុវត្តនូវបទប្បញ្ញត្តិ មកចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុនៅក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ។ ដូច្នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមអំពាវនាវដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ ដែលបាននឹងកំពុងគ្រប់គ្រង និងប្រើប្រាស់បរធនបាលុកិច្ចហិរញ្ញវត្ថុ មួយចំនួនទៀតមកចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ នាយដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ភ្ញៀវជាតិ-អន្តរជាតិ**

បច្ចុប្បន្ននេះ វិស័យធានារ៉ាប់រងខ្នាតតូច ក៏បានដើរតួនាទីសំខាន់ផងដែរក្នុងការចូលរួមចំណែកកាត់បន្ថយនូវហានិភ័យក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ ក្នុងនោះមាន ផលិតផលធានារ៉ាបរងខ្នាតូចមានដូចជា÷ ការធានារ៉ាប់រងសុខភាព (health insurance) ការធានារ៉ាប់រងលើឥណទាន (credit life) ការធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល (personal accident) និងអាយុជីវិត (term life one year)។

ថ្មីៗនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានអំពាវនាវដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ ពិនិត្យលទ្ធភាពលើការជំពាក់បំណុលរបស់ប្រជាកសិករ តាមរយៈការពន្យាពេលសងបំណុល ការមិនយកការប្រាក់ ឬបន្ថយការប្រាក់ និងជៀសវាងការរឹបអូសទ្រព្យសម្បត្តិរបស់ពួកគាត់ ក្នុងករណីដែលប្រជាកសិករ ទាំងនោះពុំមានលទ្ធភាពសងប្រាក់ទាន់ពេលវេលាដោយសារប្រឈមនឹងគ្រោះរាំងស្ងួត។ ខ្ញុំមានការជឿជាក់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ នឹងបន្តចូលរួមអនុវត្តនូវសេចក្តីអំពាវនាវរបស់រាជរដ្ឋាភិបាល ដូចដែលធ្លាប់បានចូលរួមអនុវត្តកន្លងមកក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣ ដែលពេលនោះប្រទេសជាតិកំពុងជួបប្រទះនូវគ្រោះទឹកជំនន់។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ លោកប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលបានខិតខំប្រឹងប្រែងរៀបចំសន្និសីទនេះឡើង។ ខ្ញុំសង្ឃឹមថា សន្និសីទមួយថ្ងៃនេះ នឹងប្រមែប្រមូលនូវធាតុចូលសំខាន់ៗ ដើម្បីរៀបចំជាវិធានការអនុវត្តនៅឆ្នាំ២០១៦ ខាងមុខ យកទៅអនុវត្តមានប្រសិទ្ធភាពតាមរយៈការផ្តល់សេវាមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវខ្ពស់។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ភ្ញៀវជាតិអន្តរជាតិ សូមមានសុខភាពល្អ និងសម្រេចជោគជ័យគ្រប់ភារកិច្ច។

**សូមអរគុណ !**